# ការពារកូនរបស់លោកអ្នក

## ការធ្លាក់ពីទីកម្ពស់អាចការពារបាន

មានកុមារប្រមាណជា៥០នាក់ធ្លាក់ពីបង្អួច ឬយ៉ផ្ទះក្នុងមួយឆ្នាំៗ។ គួរឲ្យខ្លោចផ្សាណាស់ មានកុមារមួយចំនួនតិចបានស្លាប់ពីការធ្លាក់។ មានជំហានមួយចំនួនដែលលោកអ្នកអាចទទួលធ្វើតាម ដើម្បីការពារកុមារកុំឲ្យធ្លាក់ពីបង្អួច និងយ៉ផ្ទះ។

### ការពារកុំឲ្យធ្លាក់ពីបង្អួច

- ✔ ប្រាកដឲ្យបានច្បាស់ថា ទ្វារបង្អួចមិនអាចបើកចំហធំជាង១០សង់ទីម៉ែត្រឡើយ លើកលែងតែដោយមនុស្សធំ។
- ✔ ដាក់គ្រឿងប្រដាប់ការពារបង្អួចឲ្យបានជាប់ល្អ ជាមួយចម្រឹងបង្អួចមួយចំនួន ហើយត្រូវដាក់ចន្លោះនីមួយៗប្រវែងតិចជាង១០សង់ទីម៉ែត្រឲ្យឃ្លាតពីគ្នា នៅពីលើមាត់បង្អួច។
- ✔ ប្រាកដឲ្យបានច្បាស់ថា គ្រឿងប្រដាប់ទាំងឡាយអាចយកចេញបានដោយមនុស្សធំ ដើម្បីអនុញ្ញាតសំរាប់ការរត់គេចក្នុងពេលមានអាសន្ន។
- ✔ កុមារអាចមុតខ្លាំង ពីការរត់បុកកញ្ចក់បង្អួចទាប - ចំពោះកញ្ចក់បង្អួចទាប ត្រូវដាក់ឲ្យមានកញ្ចក់សុវត្ថិភាព ឬត្រូវបិទស្រទាប់ការពារកុំឲ្យកញ្ចក់បែកខ្ចាយ។
- ✔ រក្សាវត្ថុដែលកុមារអាចឡើងតោង ឬផើបឈរពីលើឲ្យនៅឆ្ងាយពីបង្អួច ដូចជាគ្រឿងតុទូកៅអី និងប្រអប់។
- ✔ ឲ្យបានដឹងអំពីបង្អួចដែលមានគ្រោះថ្នាក់ ពេលណាទៅលេងផ្ទះអ្នកផ្សេងទៀត។ ឃ្លាំពិនិត្យកូនរបស់លោកអ្នកឲ្យបានជិតស្និទ្ធ

**សូមចងចាំថា ផ្ទាំងសំណាញ់ការពាររុយមិនអាចផ្តល់ការការពារបានឡើយ។ ផ្ទាំងសំណាញ់ការពាររុយទាំងនេះគ្រោងឡើងសំរាប់តែការពារសត្វល្អិតកុំឲ្យចូលទៅក្នុងផ្ទះប៉ុណ្ណោះ ហើយមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីទប់កម្លាំងកូនក្មេងឡើយ។**

### ការពារកុំឲ្យធ្លាក់ពីយ៉ផ្ទះ

- ✔ រក្សាវត្ថុដែលក្មេងអាចតោងឡើង ឬឈរពីលើ ដូចជាគ្រឿងតុទូកៅអី និងថូផ្កាឲ្យនៅឆ្ងាយពីយ៉ផ្ទះ។
- ✔ កុំទុកគ្រឿងតុទូកៅអីដែលមានទម្ងន់ស្រាលនៅកន្លែងណាមួយពីលើយ៉ផ្ទះ - ក្មេងអាចអូសទាញវាទៅដាក់នៅក្បែរគែមយ៉ផ្ទះ។
- ✔ ប្រើកំរាលក្រាលយ៉ផ្ទះណាដែលមិនរអិល។
- ✔ ប្រាកដឲ្យបានច្បាស់ថា បង្កាន់ដៃយ៉ផ្ទះបំពេញទៅតាមស្តង់ដារសុវត្ថិភាពបច្ចុប្បន្ន។
  - ឲ្យមានកម្ពស់យ៉ាងតិចណាស់១ម៉ែត្រ ហើយកល្អមិនត្រូវឲ្យមានកម្ពស់លើសពី១.៣ម៉ែត្រឡើយ។
  - មិនត្រូវឲ្យមានចន្លោះធំជាង១០-១២.៥សង់ទីម៉ែត្រឡើយ។
  - មិនត្រូវឲ្យមានវត្ថុ ឬផ្នែកណាមួយដែលកុមារអាចប្រើសំរាប់ជាជើងកល់ដើម្បីចាប់តោង ឬឡើងលើបង្កាន់ដៃយ៉ផ្ទះឡើយ។
- ✔ បិទទ្វារ និងបង្អួចណាដែលបើកចំហទៅកាន់យ៉ផ្ទះ ពេលណាមិនប្រើយ៉ផ្ទះ។
- ✔ កុំប្រើយ៉ផ្ទះជាទីកន្លែងលេង។
- ✔ ឲ្យបានដឹងអំពីយ៉ផ្ទះដែលមានគ្រោះថ្នាក់ ពេលណាទៅលេងផ្ទះអ្នកផ្សេងទៀត ហើយមិនត្រូវទុកក្មេងឲ្យនៅពីលើយ៉ផ្ទះឲ្យសោះពេលណាពុំមានមនុស្សធំនៅជាមួយ។

**ដើម្បីទទួលយកពត៌មានច្រើនថែមទៀត ឱវាទ និងធនធានពហុវប្បធម៌ សូមបើកមើលវិបសាយ**

**www.health.nsw.gov.au/childsafety**

NSW GOVERNMENT | Health

H09/65079